# កញ្ចប់ព័ត៌មានអំពីបណ្ដឹងសាទុក្ខច្បាប់ Lanterman

ច្បាប់ Lanterman បង្កើតលក្ខណៈវិនិច្ឆ័យស្របច្បាប់ និងសេវានានាដែលមានចំពោះប្រជាពលរដ្ឋនៅក្នុងរដ្ឋកាលីហ្វ័រញ៉ាដែលមានលក្ខខណៈសម្បត្តិគ្រប់គ្រាន់ និងមានពិការភាពបញ្ញា និងអភិវឌ្ឍន៍។ កញ្ចប់ព័ត៌មាននេះពន្យល់អំពីនីតិវិធីបណ្ដឹងសាទុក្ខនៅក្រោមច្បាប់ Lanterman។ នីតិវិធីនេះអាចប្រើប្រាស់បាននៅពេលបុគ្គលម្នាក់ៗចង់ដាក់បណ្ដឹងសាទុក្ខចំពោះសេចក្ដីសម្រេចរបស់មជ្ឈមណ្ឌលតំបន់ដែលថាពួកគេមិនមានលក្ខណៈសម្បត្តិសមស្របសម្រាប់សេវាច្បាប់ Lanterman ឬដាក់បណ្ដឹងសាទុក្ខចំពោះសេចក្ដីសម្រេចរបស់មជ្ឈមណ្ឌលតំបន់អំពីប្រភេទ ឬចំនួននៃសេវាកម្ម។

កញ្ចប់នេះនិយាយអំពីមជ្ឈមណ្ឌលតំបន់។ នីតិវិធីបណ្ដឹងសាទុក្ខក៏អនុវត្តចំពោះនរណាម្នាក់ដែលកំពុងរស់នៅក្នុងមណ្ឌលដែលប្រតិបត្តិការដោយរដ្ឋផងដែរ៖ មជ្ឈមណ្ឌលអភិវឌ្ឍន៍ Porterville មជ្ឈមណ្ឌលអភិវឌ្ឍន៍ Fairview (មជ្ឈមណ្ឌលវិបត្តិស្រួចស្រាវ STAR), មណ្ឌលសហគមន៍ Canyon Springs និងមណ្ឌល STAR (សមាហរណកម្មជំនួយបណ្ដោះអាសន្នលំនឹងឡើងវិញ)។ នីតិវិធីសម្រាប់ដាក់បណ្ដឹងសាទុក្ខចំពោះសេចក្ដីសម្រេចរបស់មជ្ឈមណ្ឌលប្រតិបត្តិការដោយរដ្ឋគឺដូចគ្នានឹងការពណ៌នានៅក្នុងកញ្ចប់នេះ។

មានកញ្ចប់ព័ត៌មានផ្សេងមួយសម្រាប់បុគ្គលទាំងឡាយដែលទទួលបានសេវា Start ដើមដំបូង។ សេវា Start ដើមដំបូងគឺសម្រាប់កុមារអាយុក្រោម 3 ឆ្នាំដែលមានលក្ខណៈសម្បត្តិសមស្របសម្រាប់សេវាមជ្ឈមណ្ឌលតំបន់ដោយសារតែមានជំងឺក្រិនលក្ខខណ្ឌ ឬកត្តាហានិភ័យមួយចំនួន។

កញ្ចប់នេះត្រូវបានធ្វើឡើងដោយមានធាតុចូលពីសហគមន៍។ យើងសូមកោតសរសើរចំពោះការរួមចំណែកអំពីអ្នកស្ម័យគាំពារ គ្រួសារ អង្គការគាំពារ អង្គការសហគមន៍ និងមជ្ឈមណ្ឌលតំបន់។ ធាតុចូលរបស់លោកអ្នកអំពីកញ្ចប់នេះ និងទស្សនៈអំពីរបៀបចែកចាយព័ត៌មាននេះឲ្យបានល្អបំផុតគឺមានតម្លៃក្រៃលែង។ ក្រសួងសេវាអភិវឌ្ឍន៍ (DDS) សូមកោតសរសើរចំពោះលោកអ្នកដែលបានចំណាយពេលនិងការខិតខំប្រឹងប្រែងធ្វើឲ្យកញ្ចប់ព័ត៌មាននេះមានសារៈសំខាន់ចំពោះបុគ្គលទាំងឡាយដែលមានពិការភាពបញ្ញា និងអភិវឌ្ឍន៍ និងគ្រួសាររបស់ពួកគេ។

ប្រសិនបើអ្នកត្រូវការកំណែកញ្ចប់ព័ត៌មាននេះជាក្រដាស សូមព្រីនវាពីគេហទំព័រ DDS៖ https://www.dds.ca.gov/general/appeals-complaints-comments/infopacket.pdf, ឬក៏ទាក់ទង៖

- អ្នកសម្របសម្រួលសេវាមជ្ឈមណ្ឌលតំបន់របស់អ្នក
- អ្នកគាំពារសិទ្ធិអតិថិជនរបស់អ្នក (CRA) តាមលេខ៖
  - (800) 390-7032 សម្រាប់រដ្ឋ California ខាងជើង ឬ
  - (866) 833-6712 សម្រាប់រដ្ឋ California ខាងត្បូង ឬ
  - ស្វែងរកអ្នកគាំពារសិទ្ធិអតិថិជនរបស់អ្នកនៅមជ្ឈមណ្ឌលតំបន់របស់អ្នកតាមអាសយដ្ឋាននេះ៖ https://www.disabilityrightsca.org/what-we-do/programs/office-of-clients-rights-advocacy-ocra/ocra-staff-links
- ការិយាល័យ Ombudsperson តាមលេខ (877) 658-9731 ឬ Ombudsperson@dds.ca.gov

របៀបប្រើប្រាស់កញ្ចប់ព័ត៌មាននេះ

កញ្ចប់ព័ត៌មាននេះផ្តល់ព័ត៌មានដល់អ្នកអំពីនីតិវិធីបណ្តឹងសារទុក និងសិទ្ធិរបស់អ្នក។ មានតំណភ្ជាប់ (links) នៅទូទាំងកញ្ចប់ព័ត៌មាននេះទៅកាន់សន្លឹកផ្តល់ព័ត៌មានសំខាន់ៗ និងធនធានផ្សេងទៀតដែលផ្តល់ព័ត៌មានបន្ថែម។ ផ្នែកទាំងដប់នៃកញ្ចប់ព័ត៌មានអំពីនីតិវិធីបណ្តឹងសាទុក្ខមានដូចខាងក្រោម។ ចុចលើផ្នែកណាមួយខាងក្រោមដើម្បីទទួលបានព័ត៌មានបន្ថែម៖


1. ទិដ្ឋភាពសង្ខេបអំពីនីតិវិធីបណ្តឹងសាទុក្ខ
2. ការទទួលជំនួយទាក់ទងនឹងបណ្តឹង
3. ការជូនដំណឹងអំពីវិធានការ
4. កាលកំណត់របស់បណ្តឹង និងរបៀបដាក់បណ្តឹង
5. សិទ្ធិបណ្តឹងសាទុក្ខ
6. កិច្ចប្រជុំក្រៅផ្លូវការ
7. ការនាំសម្រុះសម្រួល
8. សវនការ
9. បន្ទាប់ពីសេចក្តីសម្រេចរបស់សវនការ
10. នីតិវិធីបណ្តឹង តារាងលំហូរ ដែលមានកាលកំណត់


# ទិដ្ឋភាពរួមនៃនីតិវិធីបណ្តឹង

តើបណ្តឹងសាទុក្ខជាអ្វី?

បណ្តឹងសាទុក្ខគឺជាវិធីមួយក្នុងការដោះស្រាយការមិនព្រមព្រៀងគ្នាជាមួយមជ្ឈមណ្ឌលតំបន់របស់អ្នក។ ឧទាហរណ៍អំពីការមិនព្រមព្រៀងគ្នាអាចជា៖

- មជ្ឈមណ្ឌលតំបន់របស់អ្នកចង់កាត់ចំនួនម៉ោងដែលអ្នកទទួលសម្រាប់សេវា (IPP) ផែនការកម្មវិធីបុគ្គល។ អ្នកចង់រក្សាម៉ោងសេវារបស់អ្នកឲ្យនៅដដែល។
- អ្នកបានស្នើសុំមជ្ឈមណ្ឌលតំបន់ឲ្យផ្តល់សេវាថ្មី។ មជ្ឈមណ្ឌលតំបន់បាននិយាថាសេវាកម្មនេះមិនចាំបាច់។
- អ្នកបានដាក់ពាក្យសុំសេវាពីមជ្ឈមណ្ឌលតំបន់។ មជ្ឈមណ្ឌលតំបន់បាននិយាយថាអ្នកមិនមានលក្ខណ:សម្បត្តិគ្រប់គ្រាន់។
- បច្ចុប្បន្ន អ្នកទទួលបានសេវាពីមជ្ឈមណ្ឌលតំបន់។ មជ្ឈមណ្ឌលតំបន់បាននិយាយថាអ្នកលែងមានលក្ខណ:សម្បត្តិទៀតហើយ។

ប្រសិនបើអ្នក និងមជ្ឈមណ្ឌលតំបន់មិនឯកភាពគ្នាទេ អ្នកមានសិទ្ធិដាក់បណ្តឹងចំពោះការសម្រេចរបស់មជ្ឈមណ្ឌលតំបន់។

## ការជូនដំណឹងអំពីវិធានការ (NOA)

អ្នកទទួលបានការជូនដំណឹងអំពីវិធានការ (NOA) នៅពេលអ្នក និងមជ្ឈមណ្ឌលតំបន់មិនឯកភាពគ្នា។ អ្នកនឹងទទួលបាន NOA តាមរយៈមជ្ឈមណ្ឌលតំបន់ ដើម្បីជម្រាបអ្នកអំពីហេតុផលនានានៃការសម្រេចនេះ។ NOA ជម្រាបអ្នកអំពីកាលបរិច្ឆេទដែលការសម្រេចនឹងត្រូវធ្វើឡើង។ NOA ពណ៌នាអំពីសិទ្ធិបណ្ដឹងសាទុក្ខរបស់អ្នក និងផ្ដល់ជូននូវទម្រង់សំណើបណ្ដឹងសាទុក្ខ។

អ្នកនឹងមិនទទួលបាន NOA ឡើយប្រសិនបើអ្នកនិងមជ្ឈមណ្ឌលតំបន់ព្រមព្រៀងគ្នាលើសេចក្ដីសម្រេច។ កិច្ចព្រមព្រៀងនេះត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ។ កិច្ចព្រមព្រៀងរបស់អ្នកហៅថា "ការយល់ព្រមគ្នាទៅវិញទៅមក"។

## របៀបស្នើសុំដាក់បណ្ដឹង

អ្នកដាក់ទម្រង់សំណើបណ្ដឹងសាទុក្ខទៅកាន់ DDS ដើម្បីចាប់ផ្ដើមបណ្ដឹងរបស់អ្នក។ NOA ផ្ដល់ទម្រង់សំណើបណ្ដឹង ទម្រង់សំណើបណ្ដឹងតាមអនឡាញក៏មាននៅក្នុងអាសយដ្ឋាននេះដែរ៖ https://www.dds.ca.gov/general/appeals-complaints-comments/forms/ARF

- វិធីលឿនបំផុតក្នុងការស្នើសុំដាក់បណ្ដឹងគឺតាមអនឡាញនៅលើគេហទំព័រ DDS តាមតំណភ្ជាប់ខាងលើ។
- អ្នកអាចផ្ញើទម្រង់នេះតាមអ៊ីមែលទៅកាន់ appealrequest@dds.ca.gov។ អ្នកអាចទាញយកច្បាប់ចម្លងជាក្រដាសពីគេហទំព័រដដែលនេះ។
- ប្រសិនបើអ្នកចង់ផ្ញើទម្រង់នេះតាមអ៊ីមែល ចូរផ្ញើសំណើរបស់អ្នកទៅកាន់អាសយដ្ឋាន៖
  Office of Community Appeals and Resolutions
  1215 O Street MS 8-20
  Sacramento, CA 95814
- អ្នកអាចផ្ញើទូរសារទម្រង់នេះទៅកាន់លេខ 916-654-3641។

អ្នកនឹងទទួលបានអ៊ីមែល ឬលិខិតពី DDS ដែលបញ្ជាក់ថាគេបានទទួលសំណើបណ្ដឹងរបស់អ្នកហើយ។

## កាលកំណត់ក្នុងការដាក់សំណើបណ្ដឹងសាទុក្ខ

អ្នកត្រូវតែដាក់សំណើបណ្ដឹងសាទុក្ខរបស់អ្នកឲ្យទាន់ពេលវេលា។ មានកាលកំណត់ចំនួនពីរ។

- ដើម្បីរក្សាទុកសេវាកម្មបច្ចុប្បន្នរបស់អ្នកឲ្យនៅដដែលនៅអំឡុងពេលដាក់បណ្ដឹងសាទុក្ខរបស់អ្នក សំណើរបស់អ្នកត្រូវតែបោះត្រាប្រៃសណីយ៍ ឬទទួលដោយ DDS មិនឲ្យហួសពីរយៈពេល 30 ថ្ងៃចាប់ពីអ្នកបានទទួល NOA របស់អ្នក និងមុនពេលវិធានការកើតឡើង។
  ការរក្សាទុកសេវាកម្មបច្ចុប្បន្នរបស់អ្នកឲ្យនៅដដែលនៅអំឡុងពេលបណ្ដឹងសាទុក្ខត្រូវបានហៅថាការរង់ចាំប្រាក់ជំនួយ (aid paid pending)។
- ប្រសិនបើសំណើបណ្ដឹងសាទុក្ខរបស់អ្នកត្រូវបានដាក់ក្នុងពេលពី 31 ដល់ 60 ថ្ងៃចាប់ពីពេលដែលអ្នកទទួលបាន NOA របស់អ្នក ការសម្រេចរបស់មជ្ឈមណ្ឌលតំបន់នឹងត្រូវធ្វើឡើងនៅខណៈដែលបណ្ដឹងរបស់អ្នកបន្ត។
- សំណើបណ្ដឹងសាទុក្ខទាំងអស់ត្រូវតែដោះត្រាប្រៃសណីយ៍ ឬទទួលដោយ DDS មិនឲ្យហួសពី 60 ថ្ងៃចាប់ពីពេលដែលអ្នកទទួលបាន NOA របស់អ្នក។

សិទ្ធិបណ្ដឹងសាទុក្ខ

នៅអំឡុងពេលបណ្ដឹងសាទុក្ខនេះ អ្នកមានសិទ្ធិខាងផ្លូវច្បាប់មួយចំនួន។ សិទ្ធិទាំងនេះមានពណ៌នានៅក្នុង NOA របស់អ្នក។ ការបរិយាយលម្អិតបន្ថែមអំពីសិទ្ធិរបស់អ្នកក៏មានបង្ហាញនៅក្នុងអាសយដ្ឋាននេះផងដែរ៖ https://www.dds.ca.gov/general/appeals-complaints-comments/appealrights.pdf។

អ្នកមានសិទ្ធិដាក់បណ្ដឹងសាទុក្ខប្រសិនបើអ្នកមិនយល់ព្រមចំពោះសេចក្ដីសម្រេច ឬចំណាត់ការណាមួយដែលធ្វើឡើងដោយមជ្ឈមណ្ឌលតំបន់។ សំណើបណ្ដឹងសាទុក្ខរបស់អ្នកត្រូវតែដាក់ក្នុងរយៈពេល 60 ថ្ងៃនៃការជូនដំណឹងអំពីការសម្រេច ឬចំណាត់ការ។

អំឡុងពេលបណ្ដឹង អ្នកមានសិទ្ធិដូចតទៅ៖

- ទទួលបានការជូនដំណឹង និងព័ត៌មានគ្រប់គ្រាន់ជាភាសាដែលអ្នកចូលចិត្តប្រើ និងអាចយល់បាន។
- ទទួលបានព័ត៌មានតាមសំបុត្រ អ៊ីមែល ឬវិធីផ្សេងទៀតដែលអ្នកជ្រើសរើស។
- ជ្រើសរើសនីតិវិធីបណ្ដឹងសាទុក្ខដែលអ្នកចង់បាន។ នេះអាចជាកិច្ចប្រជុំក្រៅផ្លូវការ ការនាំសម្រុះសម្រួល ឬសវនការ។ អ្នកអាចកែតម្រូវសំណើបណ្ដឹងសាទុក្ខរបស់អ្នកនៅពេលណាក៏បាន ហើយអ្នកអាចចូលរួមក្នុងកិច្ចប្រជុំក្រៅផ្លូវការ ការនាំសម្រុះសម្រួល ឬសវនការតាមទូរសព្ទ វីដេអូ ឬដោយផ្ទាល់។
- រក្សាទុកសេវាកម្មបច្ចុប្បន្នរបស់អ្នកនៅអំឡុងពេលបណ្ដឹងសាទុក្ខ ប្រសិនបើសំណើបណ្ដឹងសាទុក្ខរបស់អ្នកត្រូវបាន DDS ទទួល ឬបោះត្រាប្រៃសនីយ៍រយៈពេល 30 ថ្ងៃបន្ទាប់ពីអ្នកទទួលបានការជូនដំណឹងស្ដីពីវិធានការ និងមុនពេលវិធានការកើតឡើង។
- ចូលប្រើប្រាស់កំណត់ត្រារបស់មជ្ឈមណ្ឌលតំបន់អំពីអ្នក។
- ជ្រើសរើសពេលវេលា និងកន្លែងសមស្របសម្រាប់កិច្ចប្រជុំក្រៅផ្លូវការ ការនាំសម្រុះសម្រួល ឬសវនការរបស់អ្នក។
- ឲ្យនរណាម្នាក់ជួយ ឬគាំទ្រអ្នកនៅអំឡុងពេលបណ្ដឹងសាទុក្ខរបស់អ្នក។ វាអាចជាមេធាវី ឬមនុស្សម្នាក់ផ្សេងដូចជាអ្នកតំណាងស្របច្បាប់របស់អ្នកជាដើម។
- អ្នកក៏អាចឲ្យមេធាវីចូលរួមក្នុងផ្នែកណាមួយនៃបណ្ដឹងរបស់អ្នកបានដែរ។ អ្នកត្រូវតែប្រាប់មជ្ឈមណ្ឌលតំបន់ជាមុនប្រសិនបើអ្នកនឹងមានមេធាវីចូលរួមក្នុងកិច្ចប្រជុំក្រៅផ្លូវការ ការនាំសម្រុះសម្រួល ឬសវនការ។
- ទទួលបានអ្នកបកប្រែដែលអាចបកប្រែយ៉ាងមានប្រសិទ្ធភាព ត្រឹមត្រូវ និងអព្យាក្រឹត។
- ស្នើសុំពេលវេលាបន្ថែម ប្រសិនបើអ្នកត្រូវការ។
- ស្នើសុំអ្នកនាំសម្រុះសម្រួល ឬមន្ត្រីសវនការផ្សេង ប្រសិនបើអ្នកគិតថាពួកគេមិនប្រកាន់យុត្តិធម៌។
- ចូលរួមគ្រប់ផ្នែកនៃបណ្ដឹងសាទុក្ខទាំងអស់។
- ជ្រើសរើសថាតើអ្នកចង់ឲ្យសវនការរបស់អ្នកបើក ឬបិទចំពោះសាធារណជនដែរឬទេ។
- អ្នកមានសិទ្ធិបញ្ចេញមតិដោយសេរី និងដោយចំហនៅក្នុងសវនការ។ មន្ត្រីសវនការនឹងស្ដាប់អ្នក សួរសំណួរ និងប្រមូលឯកសារពីអ្នក ហើយមជ្ឈមណ្ឌលតំបន់កត់ត្រាអង្គហេតុនៅក្នុងកំណត់ត្រាផ្លូវការ។
- ផ្ដល់ព័ត៌មានដល់មន្ត្រីសវនការដើម្បីគាំទ្រដល់បណ្ដឹងរបស់អ្នក។
- មានសាក្សីផ្ដល់សក្ខីកម្មក្នុងនាមអ្នក។
- ចោទសួរសាក្សីរបស់មជ្ឈមណ្ឌលតំបន់។

## ព័ត៌មានជាភាសាដែលអ្នកចូលចិត្តប្រើ

អ្នកកំណត់ភាសាដែលអ្នកចូលចិត្តប្រើ និងអាចស្នើសុំអ្នកបកប្រែនៅលើទម្រង់សំណើបណ្ដឹងសារទុក។ អ្នកនឹងទទួលបានអ្នកបកប្រែនៅគ្រប់ផ្នែកទាំងអស់នៃបណ្ដឹង ប្រសិនបើភាសាដែលអ្នកចូលចិត្តប្រើខុសពីភាសាអង់គ្លេស។ អ្នកបកប្រែត្រូវតែអាចបកប្រែយ៉ាងមានប្រសិទ្ធភាព ចំសេចក្ដី និងអព្យាក្រឹត។ មជ្ឈមណ្ឌលតំបន់ផ្ដល់ជូនអ្នកបកប្រែនៅក្នុងកិច្ចប្រជុំក្រៅផ្លូវការរបស់អ្នក។ មន្ត្រីសវនការផ្ដល់អ្នកបកប្រែសម្រាប់ការនាំសម្រុះសម្រួល និងសវនការ។

សេចក្ដីជូនដំណឹងអំពីវិធានការ (NOA) និងឯកសារផ្សេងទៀតរបស់អ្នក និងទម្រង់នានាត្រូវតែសរសេរជាភាសាដែលអ្នកចូលចិត្តប្រើ។ ប្រសិនបើអ្នកទទួលព័ត៌មាន លិខិត ឬទម្រង់ដែលមិនមែនជាភាសារបស់អ្នកទេ អ្នកអាចស្នើឲ្យមជ្ឈមណ្ឌលតំបន់ជួយបកប្រែឲ្យ។

## ផ្នែកនៃនីតិវិធីបណ្ដឹងសាទុក្ខ

នីតិវិធីនៃបណ្ដឹងសាទុក្ខមានបីផ្នែក។ អ្នកអាចប្រើផ្នែកមួយ ឬច្រើននៃផ្នែកទាំងនេះ។ ជ្រើសរើសផ្នែកដែលអ្នកចង់ប្រើប្រាស់នៅលើទម្រង់សំណើបណ្ដឹងរបស់អ្នក។ ប្រសិនបើអ្នកមិនដោះស្រាយការមិនព្រមព្រៀងគ្នាដោយប្រើផ្នែកមួយ អ្នកអាចសម្រេចចិត្តប្រើប្រាស់ផ្នែកផ្សេង។ ផ្នែកទាំងបីនៃនីតិវិធីបណ្ដឹងមាន៖

1. <u>កិច្ចប្រជុំក្រៅផ្លូវការ</u>
   អ្នកជួបជាមួយនាយកមជ្ឈមណ្ឌលតំបន់ ឬនរណាម្នាក់ដែលពួកគេជ្រើសតាំង។ អ្នកនិងមជ្ឈមណ្ឌលតំបន់នឹងព្យាយាមដោះស្រាយបណ្ដឹងរបស់អ្នក។

2. <u>ការនាំសម្រុះសម្រួល</u>
   អ្នកនិងមជ្ឈមណ្ឌលតំបន់ជួបជាមួយអ្នកនាំសម្រុះសម្រួល។ អ្នកនាំសម្រុះសម្រួលគឺជាមនុស្សដែលមិនលម្អៀង។ អ្នកនាំសម្រុះសម្រួលមិនធ្វើការសម្រាប់មជ្ឈមណ្ឌលតំបន់ឡើយ។ អ្នកនាំសម្រុះសម្រួលព្យាយាមជួយអ្នក និងមជ្ឈមណ្ឌលតំបន់បង្កើតការព្រមព្រៀងអំពីសេចក្ដីសម្រេចរបស់មជ្ឈមណ្ឌលតំបន់។ ប្រសិនបើអ្នកមិនយល់ព្រមទេ អ្នកអាចប្រើផ្នែកផ្សេងទៀតនៃនីតិវិធីបណ្ដឹង។

3. <u>សវនការ</u>
   សវនការរបស់អ្នកគឺធ្វើឡើងជាមួយមន្ត្រីសវនការ។ មន្ត្រីសវនការមិនធ្វើការសម្រាប់មជ្ឈមណ្ឌលតំបន់ឡើយ។ មន្ត្រីសវនការស្ដាប់ព័ត៌មានរបស់អ្នក និងមជ្ឈមណ្ឌលតំបន់។ មន្ត្រីសវនការជួយអ្នកបញ្ចេញអង្គហេតុរបស់អ្នក។ មន្ត្រីសវនការធ្វើឲ្យសវនការយុត្តិធម៌ និងមិនផ្លូវការ។ បន្ទាប់មកមន្ត្រីសវនការចេញសេចក្ដីសម្រេចអំពីបញ្ហានានានៅក្នុងបណ្ដឹងសាទុក្ខរបស់អ្នក។

## មេធាវី

មនុស្សគ្រប់រូបមានសិទ្ធិទទួលបានជំនួយពីមេធាវីនៅអំឡុងនីតិវិធីបណ្ដឹងសាទុក្ខដូចជាអ្នកជាដើម។ ប៉ុន្តែ មជ្ឈមណ្ឌលតំបន់អាចមានមេធាវីចូលរួមនៅក្នុងកិច្ចប្រជុំក្រៅផ្លូវការ ការនាំសម្រុះសម្រួល ឬសវនការតែប្រសិនបើអ្នកមានមេធាវីចូលរួមជាមួយអ្នក។ អ្នកត្រូវតែប្រាប់មជ្ឈមណ្ឌលតំបន់ជាមុនប្រសិនបើអ្នកនឹងមានមេធាវីចូលរួមក្នុងការនាំសម្រុះសម្រួល ឬសវនការ។ អ្នកនាំសម្រុះសម្រួល ឬមន្ត្រីសវនការអាចអនុញ្ញាតឲ្យមេធាវីចូលរួមបានប្រសិនបើពួកគេយល់ថាការធ្វើដូច្នេះនឹងនាំមកនូវយុត្តិធម៌ ប៉ុន្តែនេះជាករណីកម្រ។

### កាលកំណត់សម្រាប់ការបញ្ចប់បណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខត្រូវតែបញ្ចប់ក្នុងរយៈពេល 90 ថ្ងៃបន្ទាប់ពី DDS បានទទួលទម្រង់សំណើបណ្តឹងសាទុក្ខរបស់អ្នក។ កាលកំណត់ទាំងនេះអាចពន្យារបានប្រសិនបើអ្នក ឬមជ្ឈមណ្ឌលតំបន់ស្នើសុំបន្ត។ តារាងនេះ (https://www.dds.ca.gov/general/appeals-complaints-comments/timeline.pdf) បង្ហាញអ្នកអំពីកាលកំណត់បណ្តឹងសាទុក្ខ។

ប្រសិនបើអ្នកត្រូវការជំនួយ សូមអានផ្នែកទី 2 នៃកញ្ចប់នេះ។

## ការទទួលជំនួយទាក់ទងនឹងបណ្តឹងសាទុក្ខរបស់អ្នក

ប្រសិនបើអ្នកមានចម្ងល់អំពីការដាក់សំណើបណ្តឹងសាទុក្ខ ឬអំពីស្ថានភាពនៃបណ្តឹងរបស់អ្នក អ្នកអាចផ្ញើអ៊ីមែលទៅ appealrequest@dds.ca.gov

អ្នកអាចទទួលបានជំនួយពាក់ព័ន្ធសំណើបណ្តឹងសាទុក្ខរបស់អ្នក។ អ្នកដែលអាចជួយអ្នកបានមាន៖

- អ្នកសម្របសម្រួលសេវាកម្មរបស់អ្នក ឬបុគ្គលិកមជ្ឈមណ្ឌលតំបន់ផ្សេងទៀត ប្រសិនបើអ្នកសាកសួរពួកគេ។
- អ្នកគាំពារសិទ្ធិអតិថិជនរបស់អ្នក (CRA) តាមលេខ៖
    - (800) 390-7032 សម្រាប់រដ្ឋ California ខាងជើង ឬ
    - (866) 833-6712 សម្រាប់រដ្ឋ California ខាងត្បូង ឬ
    - ស្វែងរកអ្នកគាំពារសិទ្ធិអតិថិជនរបស់អ្នកនៅមជ្ឈមណ្ឌលតំបន់របស់អ្នកតាមអាសយដ្ឋាននេះ៖ https://www.disabilityrightsca.org/what-we-do/programs/office-of-clients-rights-advocacy-ocra/ocra-staff-links
- ការិយាល័យ Ombudsperson តាមលេខ (877) 658-9731 ឬ Ombudsperson@dds.ca.gov។ ប្រសិនបើអ្នកស្ថិតនៅក្នុងកម្មវិធី Self-Determination ចូរផ្ញើអ៊ីមែលទៅ sdp.ombudsperson@dds.ca.gov ជាជំនួសវិញ។
- អ្នកក៏អាចទទួលបានជំនួយពីមជ្ឈមណ្ឌលធនធានគ្រួសារផងដែរ៖ https://frcnca.org/get-connected/។
- មជ្ឈមណ្ឌលតំបន់របស់អ្នកអាចជួយអ្នកស្វែងរកក្រុមគាំទ្រឪពុកម្តាយក្នុងមូលដ្ឋាន ឬអង្គការនៅក្នុងសហគមន៍ដែលអាចជួយអ្នកបាន។

## ការជូនដំណឹងអំពីវិធានការ

### នៅពេលដែលអ្នកទទួលបានការជូនដំណឹងអំពីវិធានការ (NOA)

មជ្ឈមណ្ឌលតំបន់នឹងផ្ញើ NOA ជាលាយលក្ខណ៍អក្សរជូនអ្នកនៅពេលអ្នក និងមជ្ឈមណ្ឌតំបន់មិនព្រមព្រៀងគ្នាអំពីសេវា ឬលក្ខណៈសម្បត្តិសមស្របរបស់អ្នកសម្រាប់សេវានានា។ គំរូ NOA មាននៅទីនេះ ដូច្នេះអ្នកអាចមើលឃើញពីលក្ខណៈរបស់វា៖ https://www.dds.ca.gov/general/appeals-complaints-comments/forms/NOA

### នៅពេលអ្នកនឹងមិនទទួលបាន NOA

មជ្ឈមណ្ឌលតំបន់មិនផ្ញើ NOA ជូនអ្នកឡើយប្រសិនបើអ្នកយល់ព្រមចំពោះសេចក្តីសម្រេចរបស់មជ្ឈមណ្ឌលតំបន់ដែល៖

- កាត់បន្ថយ កែប្រែ ឬបញ្ឈប់ការផ្តល់សេវា
- បដិសេធសេវាថ្មីដែលអ្នកត្រូវការ
- កំណត់ថាអ្នកមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការទទួលបានសេវាពីមជ្ឈមណ្ឌលតំបន់

ការព្រមព្រៀងរបស់អ្នកចំពោះសេចក្តីសម្រេចរបស់មជ្ឈមណ្ឌលតំបន់ត្រូវតែសរសេរទុកជាឯកសារ។ ការព្រមព្រៀងនេះគេហៅថាការយល់ព្រមគ្នាទៅវិញទៅមក (https://www.dds.ca.gov/general/appeals-complaints-comments/info/mutualconsent.pdf)។ ចំណុចដែលបង្ហាញថាអ្នកព្រមព្រៀងមាន៖

- អ្នកបានចុះហត្ថលេខាលើផែនការកម្មវិធីផ្ទាល់ខ្លួន (IPP) ដោយមានការកែប្រែដែលបានស្នើសុំ ឬការជំទាស់នៅក្នុងផែនការនេះ។
- អ្នកបានចុះហត្ថលេខាលើបញ្ជីសេវាមួយដែលមានការកែប្រែដែលបានស្នើសុំ ឬការជំទាល់នៅក្នុងបញ្ជីនេះ។
- មជ្ឈមណ្ឌលតំបន់បានផ្ញើជូនអ្នកនូវលិខិតធានាអះអាងដែលថាអ្នកមិនបានជំទាស់ឡើយ។ លិខិតធានាអះអាងគំរូមាននៅទីនេះ ដូច្នេះអ្នកអាចមើលឃើញពីលក្ខណៈរបស់វា៖ https://www.dds.ca.gov/general/appeals-complaints-comments/info/goodfaithbelief.pdf។
- អ្នកបានផ្ញើជូនមជ្ឈមណ្ឌលតំបន់នូវឯកសារជាលាយលក្ខណ៍អក្សរ ឬអ៊ីមែលដែលនិយាយថាអ្នកព្រមព្រៀងជាមួយសេចក្តីសម្រេចរបស់មជ្ឈមណ្ឌលតំបន់។

## កាលកំណត់របស់មជ្ឈមណ្ឌលតំបន់សម្រាប់ការផ្ញើជូនអ្នកនូវ NOA

មជ្ឈមណ្ឌលតំបន់នឹងផ្ញើជូនអ្នកនូវ NOA
ប្រសិនបើអ្នកមិនយល់ព្រមចំពោះសេចក្តីសម្រេចរបស់មជ្ឈមណ្ឌលតំបន់អំពីសេវាដែលអ្នកបានទទួល៖

- 30 មុននឹងមជ្ឈមណ្ឌលតំបន់កាត់បន្ថយ កែប្រែ ឬឈប់ផ្តល់សេវា
- 5 ថ្ងៃធ្វើការបន្ទាប់ពីមជ្ឈមណ្ឌលតំបន់បដិសេធផ្តល់សេវា ឬការគាំទ្រដែលអ្នកចង់បន្ថែមទៅក្នុង IPP (ផែនការកម្មវិធីផ្ទាល់ខ្លួន) របស់អ្នក។

មជ្ឈមណ្ឌលតំបន់នឹងផ្ញើជូនអ្នកនូវ NOA អំពីលក្ខណសម្បត្តិសមស្របរបស់អ្នកក្នុងការទទួលបានសេវាពីមជ្ឈមណ្ឌលតំបន់៖

- 30 ថ្ងៃមុននឹងអ្នកលែងមានលក្ខណ:សម្បត្តិសមស្របក្នុងការទទួលបានសេវាពីមជ្ឈមណ្ឌលតំបន់
- 5 ថ្ងៃធ្វើការបន្ទាប់ពីអ្នកត្រូវបានបដិសេធនូវលក្ខណ:សម្បត្តិសមស្របក្នុងការទទួលបានសេវារបស់មជ្ឈមណ្ឌលតំបន់

## តើសេចក្តីជូនដំណឹងអំពីវិធានការ (NOA) ប្រាប់អ្នកពីអ្វីខ្លះ

NOA របស់អ្នកនឹងប្រាប់អ្នកថា៖

- វិធានការដែលមជ្ឈមណ្ឌលតំបន់ចង់អនុវត្ត។ នេះគឺជាការសម្រេចរបស់មជ្ឈមណ្ឌលតំនប់។
- មូលហេតុចំពោះសេចក្តីសម្រេចនេះ។
- អង្គហេតុនិងច្បាប់ ឬគោលការណ៍ដែលគាំទ្រសេចក្តីសម្រេចនេះ។
- កាលបរិច្ឆេទដែលសេចក្តីសម្រេចនឹងចូលជាធរមាន។

NOA របស់អ្នកក៏នឹង៖

- ប្រាប់អ្នកអំពីរបៀបដាក់បណ្ដឹងសាទុក្ខ។
- ផ្ដល់ជូនអ្នកនូវច្បាប់ចម្លងអំពីទម្រង់សំណើបណ្ដឹងសាទុក្ខ។
- រាប់បញ្ចូលនូវសិទ្ធិដាក់បណ្ដឹងសាទុក្ខរបស់អ្នកមួយច្បាប់។
- ប្រាប់អ្នកអំពីរបៀបទទួលជំនួយស្ដីពីបណ្ដឹងសាទុក្ខផងដែរ។

NOA របស់អ្នកនឹងធ្វើឡើងជាភាសាដែលអ្នកចូលចិត្តប្រើប្រាស់។

ប្រសិនបើអ្នកត្រូវការជំនួយ, ចូលទៅផ្នែកទី 2 នៃកញ្ចប់នេះ។

# កាលកំណត់របស់បណ្ដឹង –និងរបៀបដាក់បណ្ដឹង

## កាលកំណត់ក្នុងការដាក់បណ្ដឹងសាទុក្ខរបស់អ្នក

អ្នកត្រូវតែដាក់សំណើបណ្ដឹងសាទុក្ខរបស់អ្នកឲ្យទាន់ពេលវេលា។ មានកាលកំណត់ចំនួនពីរ។

- ដើម្បីរក្សាទុកសេវាកម្មបច្ចុប្បន្នរបស់អ្នកឲ្យនៅដដែលនៅអំឡុងពេលដាក់បណ្ដឹងសាទុក្ខរបស់អ្នក សំណើរបស់អ្នកត្រូវតែបោះត្រាប្រៃសណីយ៍ ឬទទួលដោយ DDS មិនឲ្យហួសពីរយៈពេល 30 ថ្ងៃចាប់ពីអ្នកបានទទួល NOA របស់អ្នក *និង*មុនថ្ងៃនៃការកើតឡើង។
  ការរក្សាទុកសេវាកម្មបច្ចុប្បន្នរបស់អ្នកឲ្យនៅដដែលនៅអំឡុងពេលបណ្ដឹងសាទុក្ខត្រូវបានហៅថាការរង់ចាំប្រាក់ជំនួយ (aid paid pending)។
- សំណើបណ្ដឹងសាទុក្ខទាំងអស់ត្រូវតែដោះត្រាប្រៃសណីយ៍ ឬទទួលដោយ DDS មិនឲ្យហួសពី 60 ថ្ងៃចាប់ពីពេលដែលអ្នកទទួលបាន NOA របស់អ្នក។ ប្រសិនបើសំណើបណ្ដឹងសាទុក្ខរបស់អ្នកត្រូវបានដាក់ពី 31 ដល់ 60 ចាប់ពីពេលដែលអ្នកទទួលបាន NOA របស់អ្នក នោះអ្នកនឹងមិនទទួលបានប្រាក់ជំនួយរង់ចាំនោះទេ។

## កន្លែងដែលត្រូវដាក់បណ្ដឹងរបស់អ្នក

សំណើបណ្ដឹងរបស់អ្នកត្រូវតែផ្ញើទៅកាន់ DDS។

- វិធីស្នើសុំដាក់បណ្ដឹងដ៏លឿនបំផុតគឺតាមអ៊ីនធឺណិតនៅលើគេហទំព័ររបស់ DDS តាម៖ https://www.dds.ca.gov/general/appeals-complaints-comments/forms/apppealrequest។
- អ្នកអាចផ្ញើទម្រង់នេះតាមអ៊ីមែលទៅកាន់ appealrequest@dds.ca.gov។
- ប្រសិនបើអ្នកចង់ផ្ញើទម្រង់នេះតាមសំបុត្រ អាសយដ្ឋានគឺ៖
  Office of Community Appeals and Resolutions
  1215 O Street MS 8-20,
  Sacramento, CA 95814
- អ្នកអាចផ្ញើទម្រង់នេះតាមទូរសារទៅកាន់លេខ 916-654-3641

អ្នកនឹងទទួលបានអ៊ីមែល ឬលិខិតបញ្ជាក់ពី DDS ថាគេបានទទួលបណ្ដឹងរបស់អ្នកហើយ។
សូមរក្សាទុកលេខតាមដានសំណើបណ្ដឹងសាទុក្ខដែល DDS ផ្ដល់ជូនអ្នក។ DDS នឹងប្រាប់មជ្ឈមណ្ឌលតំបន់ថាអ្នកបានដាក់បណ្ដឹងសាទុក្ខ។ DDS នឹងជម្រាបការិយាល័យសវនការ ប្រសិនបើអ្នកបានស្នើសុំកិច្ចប្រជុំក្រៅផ្លូវការ ការនាំសម្រុះសម្រួល និង/ឬសវនការដែលជាផ្នែកនៃសំណើបណ្ដឹងរបស់អ្នក។

នៅលើទម្រង់សំណើបណ្តឹងសាទុក្ខរបស់អ្នក អ្នកអាចសរសេរកាលបរិច្ឆេទណាមួយ ឬពេលម៉ោងដែលអ្នកមិនទំនេរនៅក្នុងរយៈពេល 90 ថ្ងៃបន្ទាប់។ កិច្ចប្រជុំក្រៅផ្លូវការ ការនាំសម្រុះសម្រួល ឬសវនការរបស់អ្នកនឹងមិនត្រូវបានកំណត់ពេលតាមកាលបរិច្ឆេទ ឬម៉ោងពេលទាំងនេះទេ។

ប្រសិនបើអ្នកត្រូវការជំនួយ ចូលទៅផ្នែកទី 2 នៃកញ្ចប់នេះ។

# សិទ្ធិបណ្តឹងសាទុក្ខ

អ្នកមានសិទ្ធនៅអំឡុងពេលបណ្តឹងសាទុក្ខ។ សិទ្ធិទាំងនោះមានបញ្ចូលនៅក្នុងការជូនដំណឹងអំពីវិធានការ (NOA) របស់អ្នក។ ការបរិយាយលម្អិតបន្ថែមអំពីសិទ្ធិរបស់អ្នកមាននៅតាមអនឡាញនៅត្រង់នេះ៖ https://www.dds.ca.gov/general/appeals-complaints-comments/appealrights.pdf។ ទាំងនេះជាសិទ្ធិសំខាន់ៗបំផុតមួយចំនួនដែលអ្នកមាននៅជំហាននីមួយៗនៃនីតិវិធីបណ្តឹងសាទុក្ខ។

**អ្នកបកប្រែ**
ប្រសិនបើអ្នកមិនប្រើប្រាស់ភាសាអង់គ្លេសទេ អ្នកមានសិទ្ធិទទួលបានអ្នកបកប្រែ។ អ្នកបកប្រែនឹងត្រូវផ្តល់ជូនអ្នកនៅគ្រប់ផ្នែកនៃបណ្តឹងសាទុក្ខរបស់អ្នក។ អ្នកអាចស្នើសុំអ្នកបកប្រែម្នាក់នៅលើទម្រង់សំណើបណ្តឹងសាទុក្ខរបស់អ្នក។ អ្នកបកប្រែត្រូវតែអាចបកប្រែយ៉ាងមានប្រសិទ្ធភាព ចំសេចក្តី និងអព្យាក្រឹត។

**ការចូលប្រើប្រាស់កំណត់ហេតុ**
អ្នកមានសិទ្ធិចូលប្រើប្រាស់កំណត់ហេតុរបស់មជ្ឈមណ្ឌលតំបន់អំពីខ្លួនអ្នក។ អ្នកក៏អាចទទួលបានកំណត់ត្រារបស់អ្នកមួយច្បាប់ផងដែរ។ មជ្ឈមណ្ឌលតំបន់អាចគិតថ្លៃពីអ្នកសម្រាប់តម្លៃនៃការថតចម្លងជាក់ស្តែង។ ប្រសិនបើអ្នកមិនមានលទ្ធភាពបង់ប្រាក់ចំពោះកំណត់ត្រានេះទេ ចូរជម្រាប់មជ្ឈមណ្ឌលតំបន់របស់អ្នក។ អ្នកអាចទទួលបានកំណត់ត្រាដោយឥតគិតថ្លៃ។ អ្នកគួរតែទទួលបានសិទ្ធិចូលប្រើប្រាស់កំណត់ត្រារបស់អ្នកក្នុងបីថ្ងៃធ្វើការនៃសំណើរបស់អ្ន។

**រកជំនួយ ឬការគាំទ្រពីអ្នកផ្សេង**
អ្នកមានសិទ្ធិឲ្យនរណាម្នាក់ជួយ ឬគាំទ្រអ្នក។ វាអាចជាមេធាវី ឬមនុស្សម្នាក់ផ្សេងទៀត។ បុគ្គលនេះអាចជាអ្នកតំណាងស្របច្បាប់របស់អ្នក។ ប្រសិនបើអ្នកយល់ព្រម អ្នកតំណាងស្របច្បាប់របស់អ្នកនឹងទទួលបានព័ត៌មានអំពីបណ្តឹងសាទុក្ខរបស់អ្នក។

អ្នកអាចស្នើសុំមេធាវី ឬនរណាម្នាក់ផ្សេងឲ្យជួយអ្នករៀបចំសម្រាប់បណ្តឹងរបស់អ្នក។ អ្នកក៏អាចឲ្យមេធាវីចូលរួមក្នុងផ្នែកណាមួយនៃបណ្តឹងរបស់អ្នកបានដែរ។ អ្នកត្រូវតែជម្រាបមជ្ឈមណ្ឌលតំបន់យ៉ាងតិច 5 ថ្ងៃមុនការនាំសម្រុះសម្រួល ប្រសិនបើអ្នកនឹងមានមេធាវីចូលក្នុងកិច្ចសម្រុះសម្រួល។ អ្នកត្រូវតែជម្រាបមជ្ឈមណ្ឌលតំបន់យ៉ាងតិច 15 ថ្ងៃមុនសវនការ ប្រសិនបើអ្នកនឹងមានមេធាវីចូលរួមក្នុងសវនការ។ មជ្ឈមណ្ឌលតំបន់មិនអាចមានមេធាវីចូលរួមក្នុងផ្នែកណាមួយនៃបណ្តឹងឡើយលុះណាតែមេធាវីរបស់អ្នកចូលរួម។ មានករណីលើកលែងតិចតួចបំផុតចំពោះបញ្ហានេះនៅពេលមន្ត្រីសវនការអនុញ្ញាតឲ្យមានមេធាវីដើម្បីយុត្តិធម៌។

**រក្សាទុកសេវាបច្ចុប្បន្នរបស់អ្នក**
អ្នកមានសិទ្ធិបន្តសេវាដែលអ្នកបច្ចុប្បន្នអ្នកបានទទួលនៅអំឡុងបណ្តឹងសាទុក្ខនេះ។ នេះគេហៅថា "ការរង់ចាំប្រាក់ជំនួយ"។
ដើម្បីរក្សាទុកសេវារបស់អ្នក DDS ត្រូវតែទទួលបានបណ្តឹងសាទុក្ខរបស់អ្នកទាន់ពេលវេលា។
នេះមានន័យថាបណ្តឹងរបស់អ្នកត្រូវតែបានទទួល ឬបោះត្រាប្រៃសនីយ៍ 30 ថ្ងៃបន្ទាប់ពីអ្នកទទួលបានសេចក្តីជូនដំណឹងអំពីវិធានការ (NOA) និងមុនកាលបរិច្ឆេទដែលមជ្ឈមណ្ឌលតំបន់បាននិយាយថាវានឹងកែប្រែ ឬបញ្ចប់សេវារបស់អ្នក ឬបញ្ចប់លក្ខណៈសម្បត្តិសមស្របរបស់អ្នក។

**សំណើបន្តផ្នែកណាមួយនៃបណ្តឹងសាទុក្ខ**
ប្រសិនបើអ្នកត្រូវការពេលវេលាបន្ថែម អ្នកអាចស្នើសុំពេលថែមទៀត។ នេះគេហៅថាការបន្ត។
ការស្នើសុំការបន្តអាចពន្យារពេលសម្រាប់បញ្ចប់បណ្តឹងទាំងមូលរបស់អ្នក។

**ស្នើសុំអ្នកនាំសម្រុះសម្រួល ឬមន្ត្រីសវនការផ្សេង**
អ្នកអាចស្នើសុំអ្នកនាំសម្រុះសម្រួល ឬមន្ត្រីសវនការផ្សេង ប្រសិនបើអ្នកគិតថាពួកគេមិនប្រកាន់យុត្តិធម៌ ឬលម្អៀង។
អ្នកត្រូវតែធ្វើដូច្នេះមុននឹងការនាំសម្រុះសម្រួល ឬសវនការចាប់ផ្តើម។ អ្នកត្រូវតែផ្តល់ហេតុផលសម្រាប់សំណើរបស់អ្នក។

លើសពីនេះទៀតអ្នកមានសិទ្ធិដូចតទៅនេះនៅក្នុងសវនការ។

**ចូលរួមសវនកា**
អ្នកមានសិទ្ធិចូលរួមគ្រប់ផ្នែកទាំងអស់នៃសវនការ។

**ផ្តល់ព័ត៌មានដល់មន្ត្រីសវនការ។**
អ្នកផ្តល់ព័ត៌មានដល់មន្ត្រីសវនការដើម្បីគាំទ្រដល់បណ្តឹងរបស់អ្នក។ ព័ត៌មាននេះគេហៅថាភ័ស្តុតាង។ អ្នក និងអ្នកផ្សេងទៀតដែលអ្នកជ្រើសរើសអាចផ្តល់ព័ត៌មានផ្ទាល់មាត់ដល់មន្ត្រីសវនការ។ អ្នកទាំងនេះគេហៅថាសាក្សី។
អ្នកក៏អាចផ្តល់ឯកសារជាលាយលក្ខណ៍អក្សរដល់ការិយាល័យសវនការផងដែរ។

**សួរសំណួរសាក្សីរបស់មជ្ឈមណ្ឌលតំបន់**
មជ្ឈមណ្ឌលតំបន់អាចអាចមានសាក្សីចាំផ្តល់សាក្ខីកម្មនៅក្នុងសវនការ។ អ្នកមានសិទ្ធិសួរសំណួរដល់សាក្សីរបស់មជ្ឈមណ្ឌលតំបន់។

**សម្រេចថាតើសវនការនេះបើកចំហដល់សាធារណជនដែរឬទេ**
សវនការបើកចំហដល់សាធារណជន។ ប្រសិនបើអ្នកមិនចង់ឲ្យសាធារណជនចូលរួមក្នុងសវនការរបស់អ្នកទេ ចូរជម្រាបមន្ត្រីសវនការថាអ្នកចង់បានសវនការបិទទ្វារ។

**ទទួលបានសេចក្តីសម្រេចពីសវនការក្នុងរយៈពេល 90 ថ្ងៃ**
អ្នកគួរតែទទួលបានសេចក្តីសម្រេចពីសវនការក្នុងរយៈពេល 90 ថ្ងៃពីកាលបរិច្ឆេទដែលអ្នកបានដាក់សំណើបណ្តឹងសាទុក្ខ។
ពេលវេលានេះអាចពន្យាប្រសិនបើអ្នកស្នើសុំការបន្ត។
វានឹងត្រូវបានពន្យារផងដែរប្រសិនបើមជ្ឈមណ្ឌលតំបន់បានស្នើសុំការបន្តដោយមានហេតុផលសមស្រប ហើយមន្ត្រីសវនការបានយល់ព្រម។

ប្រសិនបើអ្នកត្រូវការជំនួយ ចូលទៅផ្នែកទី 2 នៃកញ្ចប់នេះ។

# កិច្ចប្រជុំក្រៅផ្លូវការ

ប្រសិនបើអ្នកបានស្នើសុំកិច្ចប្រជុំក្រៅផ្លូវការស្តីទម្រង់សំណើបណ្តឹងសាទុក្ខរបស់អ្នក វាគឺជាផ្នែកទីមួយនៃបណ្តឹងសាទុក្ខរបស់អ្នក។ កិច្ចប្រជុំក្រៅផ្លូវការធ្វើឡើងជាមួយនាយកមជ្ឈមណ្ឌលតំបន់ ឬនរណាម្នាក់ដែលពួកគេជ្រើសតាំង។ នៅក្នុងកិច្ចប្រជុំ អ្នក និងមជ្ឈមណ្ឌលតំបន់នឹងព្យាយាមដោះស្រាយក្តីបារម្ភរបស់អ្នក។

## ពេលម៉ោង និងកន្លែងកិច្ចប្រជុំក្រៅផ្លូវការ

DDS នឹងជម្រាបមជ្ឈមណ្ឌលតំបន់ថាអ្នកចង់បានកិច្ចប្រជុំក្រៅផ្លូវការ។ មជ្ឈមណ្ឌលតំបន់ទាក់ទងអ្នកដើម្បីកំណត់កាលវិភាគកិច្ចប្រជុំ។ កិច្ចប្រជុំត្រូវតែមានលក្ខណៈអំណោយផលសម្រាប់អ្នក។ កិច្ចប្រជុំអាចធ្វើឡើងដោយចំពោះមុខ តាមទូរសព្ទ ឬតាមវីដេអូទៅតាមសំណើរបស់អ្នក។ អ្នកនិងមជ្ឈមណ្ឌលតំបន់ព្រមព្រៀងគ្នាអំពីរបៀបបើកកិច្ចប្រជុំ។

កិច្ចប្រជុំក្រៅផ្លូវការត្រូវតែធ្វើឡើងមិនឲ្យហួសពីរយៈពេល 10 ថ្ងៃ បន្ទាប់ពី DDS ជម្រាបដល់មជ្ឈមណ្ឌលតំបន់អំពីសំណើរបស់អ្នក។ អ្នកអាចស្នើសុំពេលវេលាបន្ថែម។ នេះគេហៅថា "ការបន្ត"។ ការបន្តពន្យារកាលកំណត់រយៈពេល 10 ថ្ងៃ។

## អ្វីដែលកើតឡើងនៅក្នុងកិច្ចប្រជុំក្រៅផ្លូវការ

អ្នកពិភាក្សាតម្រូវការរបស់អ្នកអំពីសេវា ឧបសគ្គទាំងឡាយដែលអ្នកជួបប្រទះ និងព័ត៌មានផ្សេងទៀតដែលអ្នកចង់ចែករំលែក។ មជ្ឈមណ្ឌលតំបន់ពន្យល់ការសម្រេចរបស់ខ្លួន និងស្តាប់ព័ត៌មានដែលអ្នកចែករំលែក។ មជ្ឈមណ្ឌលតំបន់ធ្វើការងារជាមួយអ្នកដើម្បីស្វែងរកដំណោះស្រាយមួយ។

មជ្ឈមណ្ឌលតំបន់ផ្តល់អ្នកបកប្រែដែលមានសមត្ថភាពដល់អ្នកប្រសិនបើអ្នកមិនប្រើប្រាស់ភាសាអង់គ្លេស។

អ្នកអាចមានមេធាវី ឬនរណាម្នាក់ផ្សេងជួយ ឬគាំទ្រអ្នក។ អ្នកអាចស្នើសុំមេធាវី ឬនរណាម្នាក់ផ្សេងឲ្យជួយអ្នករៀបចំសម្រាប់កិច្ចប្រជុំក្រៅផ្លូវការរបស់អ្នក។ នេះអាចជាអ្នកតំណាងស្របច្បាប់ ប្រសិនបើអ្នកមាន។ មជ្ឈមណ្ឌលតំបន់មិនអាចមានមេធាវីចូលរួមក្នុងកិច្ចប្រជុំក្រៅផ្លូវការឡើយ លុះណាតែអ្នកជាមេធាវី ឬមានមេធាវីចូលរួម។

## អ្វីដែលកើតឡើងបន្ទាប់ពីកិច្ចប្រជុំក្រៅផ្លូវការ

បន្ទាប់ពីកិច្ចប្រជុំ មជ្ឈមណ្ឌលតំបន់នឹងផ្តល់សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដល់អ្នកក្នុងរយៈពេលប្រាំថ្ងៃ។ សេចក្តីសម្រេចនេះនឹងស្ថិតនៅលើសេចក្តីជូនដំណឹងនៃទម្រង់ដំណោះស្រាយ។ ឧទាហរណ៍អំពីទម្រង់នេះមាននៅទីនេះ ដូច្នេះអ្នកអាចមើលឃើញពីលក្ខណៈរបស់វា៖ https://www.dds.ca.gov/general/appeals-complaints-comments/forms/NOR.pdf។ សេចក្តីសម្រេចនឹងធ្វើឡើងជាភាសាដែលអ្នកចូលចិត្តប្រើប្រាស់។ សេចក្តីសម្រេចប្រាប់អ្នក៖

- នូវអ្វីដែលមជ្ឈមណ្ឌលតំបន់បានសម្រេចអំពីបញ្ហានីមួយៗ
- នូវអង្គហេតុនិងច្បាប់ ឬគោលការណ៍ជាក់លាក់ដែលគាំទ្រសេចក្តីសម្រេចរបស់ខ្លួន។

**ប្រសិនបើអ្នកព្រមព្រៀងចំពោះសេចក្តីសម្រេចនេះ៖**

- ចូរប្រាប់មជ្ឈមណ្ឌលតំបន់ថាអ្នកយល់ស្របតាមដោយចុះហត្ថលេខាលើសេចក្តីជូនដំណឹងអំពីទម្រង់ដំណោះស្រាយ និងផ្ញើវាទៅកាន់មជ្ឈមណ្ឌលតំបន់វិញ។
- សេចក្តីសម្រេចរបស់កិច្ចប្រជុំក្រៅផ្លូវការចូលជាធរមានក្នុងរយៈពេល 10 ថ្ងៃបន្ទាប់ពីអ្នកប្រាប់ដល់មជ្ឈមណ្ឌលតំបន់។
- បណ្តឹងសាទុក្ខរបស់អ្នកនឹងបញ្ចប់។ មជ្ឈមណ្ឌលតំបន់នឹងជម្រាបដល់ DDS និងការិយាល័យសវនការ។

**ប្រសិនបើអ្នកជំទាស់នឹងសេចក្តីសម្រេចរបស់មជ្ឈមណ្ឌលតំបន់ទាំងអស់ ឬមួយផ្នែក៖**

- ការរង់ចាំប្រាក់ជំនួយរបស់អ្នកនឹងបញ្ចប់ក្នុងរយៈពេល 10 ថ្ងៃបន្ទាប់ពីសេចក្តីសម្រេចក្រៅផ្លូវការនេះ លុះណាតែអ្នកជ្រើសរើសផ្នែកមួយទៀតនៃនីតិវិធីបណ្តឹងសាទុក្ខនេះ។ នេះមានន័យថាសេវាទាំងឡាយដែលត្រូវបានបន្តនៅអំឡុងពេលបណ្តឹងសាទុក្ខរបស់អ្នកនឹងបញ្ចប់។
- ប្រាប់មជ្ឈមណ្ឌលតំបន់ថាអ្នកចង់បន្តទៅមុខទៀតជាមួយបណ្តឹងសាទុក្ខរបស់អ្នកទាំងអស់ ឬមួយផ្នែក។
- មជ្ឈមណ្ឌលតំបន់ជម្រាបដល់ DDS និងការិយាល័យសវនការ។
- ប្រសិនបើអ្នកបានស្នើសុំការនាំសម្រុះសម្រួល ឬសវនការលើទម្រង់សំណើបណ្តឹងសាទុក្ខរបស់អ្នក ចំណុចនេះនឹងកើតឡើងនៅពេលបន្ទាប់។
- ប្រសិនបើអ្នកមិនបានស្នើសុំការនាំសម្រុះសម្រួល ឬសវនការនៅពេលអ្នកបានស្នើសុំដាក់បណ្តឹងសាទុក្ខពីដំបូងទេ អ្នកអាចធ្វើបច្ចុប្បន្នភាពសំណើបណ្តឹងសាទុក្ខរបស់អ្នកដើម្បីប្រើប្រាស់ផ្នែកនាំសម្រុះស្រួល ឬសវនការនៃនីតិវិធីបណ្តឹងរបស់អ្នក។ ជម្រាប DDS អំពីផ្នែកណាមួយដែលអ្នកចង់ប្រើប្រាស់តាមរយៈការដាក់ទម្រង់កែប្រែសំណើបណ្តឹងសាទុក្ខជាមួយលេខតាមដាន សំណើបណ្តឹងសាទុក្ខដែលអ្នកបានទទួលពី DDS។

ប្រសិនបើអ្នកត្រូវការជំនួយ ចូលទៅផ្នែកទី 2 នៃកញ្ចប់នេះ។

# ការនាំសម្រុះសម្រួល

ផ្នែកទីពីរនៃនីតិវិធីបណ្តឹងសាទុក្ខគឺការនាំសម្រុះសម្រួល។ អ្នកនិងមជ្ឈមណ្ឌលតំបន់ជួបជាមួយអ្នកនាំសម្រុះសម្រួល។ អ្នកនាំសម្រុះសម្រួលគឺជាបុគ្គលអព្យាក្រឹតដែលធ្វើការនៅការិយាល័យសវនការ។ អ្នកនាំសម្រុះសម្រួលជួយអ្នក និងមជ្ឈមណ្ឌលតំបន់បង្កើតកិច្ចព្រមព្រៀងអំពីបណ្តឹងរបស់អ្នក។

## ពេលម៉ោង និងកន្លែងសម្រាប់ការនាំសម្រុះសម្រួល

ការិយាល័យសវនការជម្រាបអ្នកនិងមជ្ឈមណ្ឌលតំបន់អំពីកាលបរិច្ឆេទ និងពេលម៉ោងនៃការនាំសម្រុះសម្រួលរបស់អ្នក។ គេនឹងមិនកំណត់កាលវិភាគនៅលើកាលបរិច្ឆេទ ឬពេលម៉ោងណាដែលអ្នកមិនទំនេរ និងដែលអ្នកបានចុះនៅលើទម្រង់សំណើបណ្តឹងសាទុក្ខរបស់អ្នក លុះណាតែអ្នកព្រមព្រៀង។

ការនាំសម្រុះសម្រួលត្រូវតែធ្វើឡើងក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទដែល DDS ទទួលបានសំណើបណ្តឹងសាទុក្ខរបស់អ្នក។ អ្នកអាចស្នើសុំការបន្តប្រសិនបើអ្នកត្រូវការពេលវេលាបន្ថែម។ ការបន្តនឹងពន្យារកាលកំណត់នៃការនាំសម្រុះសម្រួល។

ការនាំសម្រុះសម្រួលអាចត្រូវធ្វើឡើងចំពោះមុខ តាមទូរសព្ទ តាមវីដេអូ ឬតាមរយៈមធ្យោបាយអេឡិកត្រូនិកដទៃទៀតតាមសំណើរបស់អ្នក។ អ្នកនិងមជ្ឈមណ្ឌលតំបន់ និងការិយាល័យសវនការព្រមព្រៀងគ្នាអំពីរបៀបបើកកិច្ចប្រជុំ។

## អ្វីដែលកើតឡើងនៅក្នុងកិច្ចនាំសម្រុះសម្រួល

កិច្ចនាំសម្រុះសម្រួលជាញឹកញាប់គឺជាជំហានបន្ទាប់នៅក្នុងនីតិវិធីបណ្តឹងសាទុក្ខ ប្រសិនបើកិច្ចប្រជុំក្រៅផ្លូវការមិនសម្រេចបានការព្រមព្រៀងរវាងអ្នកនិងមជ្ឈមណ្ឌលតំបន់ទេនោះ។ អ្នកមិនត្រូវចូលរួមក្នុងកិច្ចប្រជុំក្រៅផ្លូវការមុនពេលស្នើសុំកិច្ចសម្រុះសម្រួល។ កិច្ចនាំសម្រុះសម្រួលមានលក្ខណៈក្រៅផ្លូវការ។ អ្នកពិភាក្សាអំពីតម្រូវការសេវារបស់អ្នក ឧបសគ្គនានាដែលអ្នកបានជួបប្រទះក្នុងការទទួលបានភាពសមស្រប ឬសេវានានា និងព័ត៌មានផ្សេងទៀតដែលអ្នកចង់ចែករំលែក។ អ្នកនាំសម្រុះសម្រួលស្តាប់អ្វីដែលអ្នកកំពុងចែករំលែក។ មជ្ឈមណ្ឌលតំបន់ពន្យល់ពីសេចក្តីសម្រេចរបស់ខ្លួន។ អ្នកនាំសម្រុះសម្រួលអាចជួបជាមួយអ្នក និងមជ្ឈមណ្ឌលតំបន់ដាច់ដោយឡែកពីគ្នា។ អ្នកនាំសម្រុះសម្រួលជួយអ្នក និងមជ្ឈមណ្ឌលតំបន់ឈានដល់កិច្ចព្រមព្រៀងមួយ។

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែសម្រាប់កិច្ចសម្រុះសម្រួលនេះ ការិយាល័យសវនការនឹងផ្តល់ជូនអ្នក។

អ្នកអាចមានមេធាវី ឬនរណាម្នាក់ផ្សេងជួយ ឬគាំទ្រអ្នកនៅក្នុងកិច្ចសម្រុះសម្រួល។ អ្នកអាចមានមេធាវី ឬនរណាម្នាក់ផ្សេងឲ្យជួយអ្នករៀបចំសម្រាប់កិច្ចសម្រុះសម្រួលរបស់អ្នក។ អ្នកត្រូវតែជម្រាបមជ្ឈមណ្ឌលតំបន់យ៉ាងតិច 5 ថ្ងៃមុនការនាំសម្រុះសម្រួល ប្រសិនបើអ្នកនឹងមានមេធាវីចូលក្នុងកិច្ចសម្រុះសម្រួលនេះ។ មជ្ឈមណ្ឌលតំបន់មិនអាចមានមេធាវីចូលរួមក្នុងការនាំសម្រុះសម្រួលឡើយ លុះណាតែអ្នកជាមេធាវី ឬមានមេធាវីចូលរួម។

ការឈានដល់ដំណោះស្រាយអាចមានកិច្ចប្រជុំសម្រុះសម្រួលលើសពីមួយដង។ អ្នកនិងមជ្ឈមណ្ឌលតំបន់អាចព្រមព្រៀងចំពោះកិច្ចប្រជុំបន្ថែមជាមួយអ្នកនាំសម្រុះសម្រួល។

## អ្វីដែលកើតឡើងនៅចុងកិច្ចនាំសម្រុះសម្រួល

**ប្រសិនបើអ្នក និងមជ្ឈមណ្ឌលតំបន់ព្រមព្រៀង៖**

- អ្នកនាំសម្រុះសម្រួល ដោយមានជំនួយពីអ្នក និងមជ្ឈមណ្ឌលតំបន់នឹងសរសេរកិច្ចព្រមព្រៀងសម្រុះសម្រួលមួយ។ កិច្ចព្រមព្រៀងនេះនឹងគូសបញ្ជាក់នូវអ្វីដែលភាគីនីមួយៗត្រូវធ្វើ និងកាលបរិច្ឆេទដែលអ្នកនឹងធ្វើវា។ អ្នកនឹងចុះហត្ថលេខាលើវា។

- អ្នក និងមជ្ឈមណ្ឌលតំបន់នឹងចុះហត្ថលេខាលើសេចក្តីជូនដំណឹងនៃទម្រង់ដំណោះស្រាយផងដែរ។ ឧទាហរណ៍អំពីទម្រង់នេះមាននៅទីនេះ ដូច្នេះអ្នកអាចមើលឃើញពីលក្ខណៈរបស់វា៖ https://www.dds.ca.gov/general/appeals-complaints-comments/forms/NOR.pdf។
- កិច្ចព្រមព្រៀងចូលជាធរមាននៅក្នុងរយៈពេល 10 ថ្ងៃបន្ទាប់ពីអ្នកព្រមព្រៀងគ្នា។

**ប្រសិនបើអ្នក និងមជ្ឈមណ្ឌលតំបន់មិនព្រមព្រៀងគ្នាលើសេចក្តីសម្រេចរបស់អ្នកនាំសម្រុះសម្រួលទាំងអស់ ឬមួយផ្នែក៖**

- អ្នក និងមជ្ឈមណ្ឌលតំបន់អាចព្រមព្រៀងធ្វើកិច្ចសម្រុះសម្រួលមួយទៀត។
- ការរង់ចាំប្រាក់ជំនួយរបស់អ្នកនឹងបញ្ចប់ក្នុងរយៈពេល 10 ថ្ងៃបន្ទាប់ពីការនាំសម្រុះសម្រួលនេះ លុះណាតែអ្នកជ្រើសរើសផ្នែកមួយទៀតនៃនីតិវិធីបណ្តឹងសាទុក្ខនេះ។ នេះមានន័យថាសេវាទាំងឡាយដែលត្រូវបានបន្តនៅអំឡុងពេលបណ្តឹងសាទុក្ខរបស់អ្នកនឹងបញ្ចប់។
- ចូរប្រាប់អ្នកនាំសម្រុះសម្រួលនិងមជ្ឈមណ្ឌលតំបន់ថាអ្នកចង់បន្តបណ្តឹងសាទុក្ខរបស់អ្នក។
- អ្នកនាំសម្រុះសម្រួលនឹងជម្រាបដល់ DDS និងការិយាល័យសវនការ។
- ប្រសិនបើអ្នកបានស្នើសុំសវនការលើទម្រង់សំណើបណ្តឹងសាទុក្ខរបស់អ្នក ចំណុចនេះនឹងកើតឡើងនៅពេលបន្ទាប់។
- ប្រសិនបើអ្នកមិនបានស្នើសុំឲ្យមានសវនការនៅពេលអ្នកបានស្នើសុំដាក់បណ្តឹងសាទុក្ខពីដំបូង អ្នកអាចធ្វើបច្ចុប្បន្នភាពសំណើបណ្តឹងសាទុក្ខរបស់អ្នកដើម្បីស្នើសុំសវនការ។ ជម្រាប DDS ថាអ្នកចង់មានសវនការតាមរយៈការដាក់ទម្រង់កែប្រែសំណើបណ្តឹងសាទុក្ខជាមួយលេខតាមដានសំណើបណ្តឹងសាទុក្ខដែលអ្នកបានទទួលពី DDS។

ប្រសិនបើអ្នកត្រូវការជំនួយ ចូលទៅផ្នែកទី 2 នៃកញ្ចប់នេះ។

# សវនការ

ផ្នែកទីបីនៃនីតិវិធីបណ្តឹងសាទុក្ខគឺសនការ។ នេះគឺជាសវនការជាមួយមន្ត្រីសវនការ។ មន្ត្រីសវនការប្រមូលព័ត៌មាន វាយតម្លៃឯកសារ និងស្តាប់ការផ្តល់សាក្សីកម្មពីអ្នក មជ្ឈមណ្ឌលតំបន់ និងសាក្សីនានា។ មន្ត្រីសវនការធ្វើសេចក្តីសម្រេចអំពីបណ្តឹងរបស់អ្នក។

## ពេលវេលា និងកន្លែងបើកសវនការ

ការិយាល័យសវនការជម្រាបអ្នកនិងមជ្ឈមណ្ឌលតំបន់អំពីកាលបរិច្ឆេទ និងពេលម៉ោងនៃសវនការរបស់អ្នក។ គេនឹងមិនកំណត់កាលវិភាគនៅលើកាលបរិច្ឆេទ ឬពេលម៉ោងណាដែលអ្នកមិនទំនេរ និងដែលអ្នកបានចុះនៅលើទម្រង់សំណើបណ្តឹងសាទុក្ខរបស់អ្នក លុះណាតែអ្នកព្រមព្រៀង។

សវនការត្រូវតែធ្វើឡើងក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទដែល DDS ទទួលបានសំណើបណ្តឹងសាទុក្ខរបស់អ្នក។ អ្នកអាចស្នើសុំការបន្តប្រសិនបើអ្នកត្រូវការពេលវេលាបន្ថែម។ ការបន្តនឹងពន្យារកាលកំណត់នៃសវនការ។

សវនការអាចត្រូវធ្វើឡើងចំពោះមុខ តាមទូរសព្ទ តាមវីដេអូ ឬតាមរយៈមធ្យោបាយអេឡិកត្រូនិកដទៃទៀតតាមសំណើរបស់អ្ន។ អ្នកនិងមជ្ឈមណ្ឌលតំបន់ និងការិយាល័យសវនការព្រមព្រៀងគ្នាអំពីរបៀបបើកសវនការ។

## អ្វីដែលកើតឡើងមុនសវនការ

មជ្ឈមណ្ឌលតំបន់ផ្តល់ជូនអ្នក និងមន្ត្រីសវនការនូវសេចក្តីថ្លែងការណ៍អំពីតួនាទីជាលាយលក្ខណ៍អក្សរចំនួនពីរថ្ងៃធ្វើការមុននឹងបើកសវនកា។ សេចក្តីថ្លែងការណ៍នេះនឹងត្រូវផ្ញើតាមអ៊ីមែល លុះណាអ្នកចង់ទទួលវាតាមវិធីផ្សេង។

សេចក្តីថ្លែងការណ៍អំពីតួនាទីត្រូវតែសរសេរជាភាសាដែលអ្នក និងអ្នកតំណាងស្របច្បាប់របស់អ្នកចូលចិត្តប្រើប្រាស់។ សេចក្តីថ្លែងការណ៍អំពីតួនាទីផ្តល់អង្គហេតុអំពីសេចក្តីសម្រេចរបស់មជ្ឈមណ្ឌលតំបន់ និងហេតុផលនានាចំពោះសេចក្តីសម្រេចនាំ។ វារួមមានព័ត៌មានអំពីសាក្សីរបស់មជ្ឈមណ្ឌលតំបន់។ វារាប់បញ្ចូលផងដែរនូវឯកសារដែលមជ្ឈមណ្ឌលតំបន់នឹងប្រើប្រាស់នៅក្នុងសវនការ។

ប្រសិនបើមេធាវីចូលរួមសវនការជាមួយអ្នក ពួកគេត្រូវតែផ្តល់សេចក្តីថ្លែងបញ្ជាក់តួនាទី និងឯកសារដែលអ្នកនឹងប្រើប្រាស់នៅក្នុងសវនការចំនួនពីរថ្ងៃការងារមុនពេលសវនការ។

ប្រសិនបើអ្នកមានមេធាវីទេ អ្នកត្រូវតែផ្តល់ជូនមជ្ឈមណ្ឌលតំបន់ និងការិយាល័យសវនការនូវព័ត៌មានមួយចំនួនក្នុងរយៈពេលពីរថ្ងៃនៃសវនការ។ ព័ត៌មានដែលអ្នកត្រូវតែចែករំលែកគឺ៖

- បញ្ជីឈ្មោះមនុស្សដែលអ្នកចង់ផ្តល់សាក្ខីកម្មនៅក្នុងសវនការ។ អ្នកត្រូវតែរៀបរាប់ពីរបៀបដែលមនុស្សទាំងនេះពាក់ព័ន្ធនឹងអ្នក។ ឧទាហរណ៍ មនុស្សនោះអាចជាសមាជិកគ្រួសារ ឬអ្នកជំនាញព្យាបាល ឬវេជ្ជបណ្ឌិត។
- ច្បាប់ចម្លងនៃរង្វាយតម្លៃវិជ្ជាជីវៈណាមួយ ឬរបាយការណ៍ដែលអ្នកនឹងប្រើប្រាស់នៅឯសវនការ។ នេះអាចជារបាយការណ៍របស់វេជ្ជបណ្ឌិត ឬអ្នកជំនាញព្យាបាល។

ប្រសិនបើអ្នកមិនមានមេធាវីទេ អ្នកអាចផ្តល់ច្បាប់ចម្លងនៃឯកសារផ្សេងទៀតនៅមុន ឬនៅពេលសវនការ។ អ្នកក៏អាចដាក់សេចក្តីថ្លែងជាលាយលក្ខណ៍អក្សរអំពីសំណុំរឿងរបស់អ្នកបានដែរ ប៉ុន្តែអ្នកមិនត្រូវផ្តល់មួយទេ។

ប្រសិនបើអ្នកមិនផ្តល់ព័ត៌មានដែលអ្នកត្រូវតែចែករំលែកទេ នោះមន្ត្រីសវនការអាចផ្តល់ពេលវេលាដល់អ្នកថែមទៀតដើម្បីទទួលបានព័ត៌មាននោះ និងបន្តសវនការ ឬបន្តសវនការដោយមិនមានព័ត៌មាននោះ ឬប្រើជម្រើសទាំងពីររួមគ្នា។

សម្រាប់ព័ត៌មានស្តីពីសិទ្ធិរបស់អ្នកនៅឯសវនការ ចូរចូលទៅផ្នែកទី 5 នៃកញ្ចប់នេះ។

## អ្វីដែលកើតឡើងនៅក្នុងសវនការ

សវនការមានលក្ខណៈបើកចំហចំពោះសាធារណជន លុះណាតែអ្នកប្រាប់មន្ត្រីសវនការថាអ្នកមិនចង់ឲ្យសាធារណជនចូលរួមទេ។

សវនការត្រូវបានធ្វើឡើងដោយមន្ត្រីសវនការ។ មន្ត្រីសវនការស្តាប់ព័ត៌មានដែលផ្តល់ដោយសាក្សីរបស់អ្នក និងរបស់មជ្ឈមណ្ឌលតំបន់។ មន្ត្រីសវនការក៏វាយតម្លៃឯកសារដែលអ្នក និងមជ្ឈមណ្ឌលតំបន់ផ្តល់ជូនផងដែរ។

មន្ត្រីសវនការត្រូវធ្វើឲ្យសវនការយុត្តិធម៌ និងមិនលំអៀង។ មន្ត្រីសវនការត្រូវតែជួយអ្នក និងមជ្ឈមណ្ឌលតំបន់ចែករំលែកអង្គហេតុ។ នេះគេហៅថា "ភាពអព្យាក្រឹតពាក់ព័ន្ធ"។ ដើម្បីជួយចែករំលែកអង្គហេតុ មន្ត្រីសវនការអាចធ្វើដូចតទៅនេះ៖

- ចោទសួរសាក្សីមួយចំនួន
- កោះហៅសាក្សីដើម្បីផ្តល់សាក្ខីកម្មនៅសវនការ និង
- នៅចុងបញ្ចប់សវនការ ផ្តល់ពេលវេលាបន្ថែមដើម្បីឲ្យសាក្សីផ្តល់សាក្ខីកម្ម ឬផ្តល់ឯកសារផ្សេងទៀត។

## កាលកំណត់ក្នុងការទទួលបានសេចក្តីសម្រេចសវនការ

ជាធម្មតាមន្ត្រីសវនការចេញសេចក្តីសម្រេចចុងក្រោយ។ សេចក្តីសម្រេចនេះធ្វើឡើង និងផ្ញើជូនអ្នក និងមជ្ឈមណ្ឌលតំបន់ក្នុងរយៈពេល 10 ថ្ងៃធ្វើការចាប់ពីថ្ងៃសវនការចុងក្រោយ។ លើសពីនេះទៀត សេចក្តីសម្រេចនេះត្រូវបានធ្វើឡើង និងផ្ញើជូនអ្នកមិនឲ្យលើសពី 80 ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលសំណើបណ្តឹងសាទុក្ខត្រូវបានទទួលដោយ DDS។ កាលកំណត់ទាំងនេះត្រូវបានពន្យារប្រសិនបើនរណាម្នាក់បានស្នើសុំពេលវេលាបន្ថែមនៅអំឡុងនីតិវិធីបណ្តឹងសាទុក្ខដែលគេហៅថា "ការបន្ត"។

ជួនកាលនាយក DDS នឹងចេញសេចក្តីសម្រេចចុងក្រោយ។ ប្រសិនបើការសម្រេចនេះកើតឡើង, DDS នឹងផ្ញើសេចក្តីសម្រេចជូនអ្នកមិនឲ្យហួសពី 90 ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទដែលសំណើបណ្តឹងសាទុក្ខត្រូវបានទទួលដោយ DDS។ កាលកំណត់នេះត្រូវបានពន្យារប្រសិនបើមានការបន្ត។

សេចក្តីសម្រេចសវនការនឹងធ្វើឡើងជាភាសាដែលអ្នកចូលចិត្តប្រើប្រាស់។ អ្នកនឹងទទួលបានច្បាប់ចម្លងជាភាសាអង់គ្លេសផងដែរ។

សេចក្តីសម្រេចរបស់វនការគឺជាសេចក្តីសម្រេចចុងក្រោយ លុះណាតែអ្នក ឬមជ្ឈមណ្ឌលតំបន់ស្នើសុំការធ្វើសេចក្តីសម្រេចឡើងវិញ។ ចំណុចនេះមានពិភាក្សានៅខាងក្រោម។

ប្រសិនបើអ្នកត្រូវការជំនួយ ចូលទៅផ្នែកទី 2 នៃកញ្ចប់នេះ។

# បន្ទាប់ពីសេចក្ដីសម្រេចរបស់សវនការ

## ការពិចារណាឡើងវិញ

បន្ទាប់ពីសវនការ អ្នក ឬមជ្ឈមណ្ឌលតំបន់អាចស្នើសុំ "ការពិចារណាឡើងវិញ"។ ការពិចារណាឡើងវិញគឺជាវិធីមួយដើម្បីកំហុសរបស់ក្រឡាបញ្ជី ឬកែតម្រូវកំហុសនៃអង្គហេតុ ឬច្បាប់នៅក្នុងសេចក្ដីសម្រេចរបស់សវនការ។ ចំណុចនេះក៏មានរាប់បញ្ចូលនូវការពិចារណាឡើងវិញអំពីសំណើដកសិទ្ធិមន្ត្រីសវនការដែលត្រូវបានបដិសេធ។ ទាំងនេះគឺជាកត្តាដែលការពិចារណាឡើងវិញអាចដោះស្រាយបាន។ អ្នកត្រូវតែស្នើសុំការពិចារណាឡើងវិញក្នុងរយៈពេល 15 ថ្ងៃបន្ទាប់ពីទទួលបានសេចក្ដីសម្រេចរបស់សវនការ។

## Aid Paid Pending បន្ទាប់ពីសេចក្ដីសម្រេចរបស់សវនការ

សេវាបច្ចុប្បន្នរបស់អ្នកនឹងបញ្ចប់៖

- 15 ថ្ងៃបន្ទាប់ពីអ្នកទទួលបានសេចក្ដីសម្រេចចុងក្រោយរបស់សវនការ លុះណាតែអ្នក ឬមជ្ឈមណ្ឌលតំបន់បានស្នើសុំការពិចារណាឡើងវិញ ឬ
- 15 ថ្ងៃបន្ទាប់ពីអ្នកទទួលបានសេចក្ដីសម្រេចពិចារណាឡើងវិញ។

## ការអនុវត្តសេចក្ដីសម្រេចពិចារណាឡើងវិញ

មជ្ឈមណ្ឌលតំបន់ត្រូវតែអនុវត្តសេចក្ដីសម្រេចចុងក្រោយរបស់សវនការ។ ការអនុវត្តនេះត្រូវតែធ្វើឡើងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងមិនឲ្យហួសពី 30 ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃសេចក្ដីសម្រេចចុងក្រោយ។ ប្រសិនបើមជ្ឈមណ្ឌលតំបន់មិនឆ្លើយតបតាមកាលកំណត់នោះទេ ពួកគេត្រូវតែប្រាប់អ្នក និង DDS។ ពួកគេត្រូវតែប្រាប់អ្នកអំពីមូលហេតុលើកលែងដែលគេមិនអាចអនុវត្តសេចក្ដីសម្រេចនោះបាន។ ពួកគេត្រូវតែប្រាប់អ្នកនៅពេលពួកគេអនុវត្តសេចក្ដីសម្រេចនេះ។ ឧទាហរណ៍គំរូនៃលិខិតដែលមជ្ឈមណ្ឌលតំបន់ត្រូវផ្ញើជូនអ្នកមាននៅទីនេះ៖ https://www.dds.ca.gov/general/appeals-complaints-comments/forms/delayletter.pdf, ដូច្នេះអ្នកអាចមើលឃើញពីលក្ខណៈរបស់វា។ ប្រសិនបើអ្នកត្រូវការជំនួយពី DDS ឲ្យគេនុវត្តសេចក្ដីសម្រេចរបស់សវនការ ចូរបំពេញទម្រង់នេះតាមអនឡាញ ឬផ្ញើវាតាមអ៊ីមែលទៅកាន់ hearingimplementation@dds.ca.gov: https://www.surveymonkey.com/r/HearingImpDelay-Consumers

## សាលាឧទ្ធរណ៍

អ្នក ឬមជ្ឈមណ្ឌលតំបន់អាចដាក់បណ្ដឹងសាទុក្ខទៅតុលាការកំពូល។ បណ្ដឹងសារទុក្ខត្រូវតែដាក់ក្នុងរយៈពេល 180 ថ្ងៃបន្ទាប់ពីសេចក្ដីសម្រេចរបស់សវនការ។ ប្រការនេះជាធម្មតាតម្រូវឲ្យអ្នកប្រើប្រាស់មេធាវី។

ប្រសិនបើអ្នកត្រូវការជំនួយ ចូលទៅផ្នែកទី 2 នៃកញ្ចប់នេះ។

# នីតិវិធីបណ្ដឹងសារទុក្ខ តារាងលំហូរ និងកាលកំណត់

ដើម្បីជួយអ្នកឲ្យយល់ពីនីតិវិធីបណ្ដឹងសាទុក្ខ, DDS បានបង្កើតតារាងលំហូរមួយ។ តារាងលំហូរបង្ហាញអ្នកនូវជំហាននានានៅក្នុងនីតិវិធីបណ្ដឹងសាទុក្ខ និងកាលកំណត់សំខាន់ៗ។ ច្បាប់ចម្លងតាមអនឡាញអំពីតារាងលំហូរនេះមាននៅទីនេះ៖https://www.dds.ca.gov/general/appeals-complaints-comments/forms/flowchart.pdf។